**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
លេខ៖ បព ១១ /២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃទស្សនកិច្ចផ្លូវការរបស់រដ្ឋមន្ត្រីការបរទេសនូវែលសេឡង់ នៅព្រះរាជាណាចក្រកម្ពុជា

តបតាមការអញ្ជើញរបស់ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា **ឯកឧត្តម វីនស្តុន ភីធឺរ** រដ្ឋមន្ត្រីការបរទេសនូវែលសេឡង់ បានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី២៨ ដល់ ២៩ ខែវិច្ឆិកា ឆ្នាំ២០២៥។ ទស្សនកិច្ចនេះ បានបញ្ជាក់ឡើងវិញពីការប្តេជ្ញាចិត្តរួមរបស់ប្រទេសទាំងពីរក្នុងការបន្តពង្រឹងទំនាក់ទំនងទ្វេភាគី និងស្វែងរកវិស័យថ្មីៗថែមទៀតសម្រាប់ធ្វើកិច្ចសហប្រតិបត្តិការ។ ក្នុងឱកាសទស្សនកិច្ចនេះ **ឯកឧត្តម វីនស្តុន ភីធឺរ** បានចូលជួបសំដែងការគួរសមចំពោះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងបានជួបពិភាក្សាជាមួយ**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន**។

ក្នុងឱកាសនៃជំនួបសម្តែងការគួរសម នៅព្រឹកថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៥ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** និង**ឯកឧត្តម វីនស្តុន ភីធឺរ** បានសម្តែងការពេញចិត្តចំពោះទំនាក់ទំនងដ៏ល្អប្រសើរ រឹងមាំ និងយូរអង្វែងនៃប្រទេសទាំងពីរ ព្រមទាំងបានបញ្ជាក់ជាថ្មីពីការបន្តពង្រឹងមិត្តភាព និងកិច្ចសហប្រតិបត្តិការ ដើម្បីសន្តិភាព វិបុលភាព និងការអភិវឌ្ឍប្រកបដោយចីរភាព នៃប្រទេសទាំងពីរ។

នៅព្រឹកថ្ងៃដដែលនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** និង**ឯកឧត្តម វីនស្តុន ភីធឺរ** បានជួបពិភាក្សាយ៉ាងស៊ីជម្រៅ ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ដែលគ្របដណ្តប់លើវិស័យជាច្រើន។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានរម្លឹកដោយអំណរគុណនូវការរួមចំណែករបស់ប្រទេសនូវែលសេឡង់ចំពោះដំណើរការស្វែងរកសន្តិភាព និងការស្តារកម្ពុជាឡើងវិញ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០ មក ជាពិសេសក្នុងកិច្ចខិតខំប្រឹងប្រែងបោសសម្អាតមីន និងការអភិវឌ្ឍធនធានមនុស្ស។ **ភាគីនូវែលសេឡង់** បានកោតសរសើរចំពោះការរីកចម្រើនយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ច និងសង្គមកម្ពុជា និងបានអះអាងជាថ្មីពីការប្តេជ្ញាចិត្តក្នុងការបន្តគាំទ្រដល់ការអភិវឌ្ឍរបស់កម្ពុជា។

ចំពោះកិច្ចសហប្រតិបត្តិការផ្នែកនយោបាយ **រដ្ឋមន្ត្រីការបរទេសទាំងពីរ** បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការរក្សាការប្រាស្រ័យទាក់ទងគ្នាជាប្រចាំនៅគ្រប់កម្រិត ដើម្បីធ្វើឱ្យទំនាក់ទំនងនយោបាយកាន់តែស៊ីជម្រៅ និងរិះរកវិស័យថ្មីៗនៃកិច្ចសហប្រតិបត្តិការ។ **ភាគីទាំងពីរ** ក៏បានស្វាគមន៍ការរៀបចំ



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

កិច្ចពិគ្រោះយោបល់លើកទី៣ រវាងក្រសួងការបរទេសកម្ពុជា និងនូវែលសេឡង់ ដែលបានប្រព្រឹត្តទៅដោយជោគជ័យ កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៥ នៅទីក្រុងវែលីងតោន និងបានឯកភាពគ្នាបន្តជំរុញការប្រើប្រាស់យន្តការសន្ទនានយោបាយនេះឱ្យបានទៀងទាត់។

ចំពោះកិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខ ដោយទទួលស្គាល់ថា ឧក្រិដ្ឋកម្មឆ្លងដែន រួមទាំងការឆបោកតាមប្រព័ន្ធអនឡាញ គឺជាការគំរាមកំហែងដ៏ធ្ងន់ធ្ងរដល់សន្តិសុខជាតិ ដែលទាមទារឱ្យមានកិច្ចសហប្រតិបត្តិការក្នុងតំបន់ **រដ្ឋមន្ត្រីការបរទេសទាំងពីរ** បានបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តយ៉ាងមោះមុតក្នុងការជំរុញកិច្ចសហប្រតិបត្តិការក្នុងវិស័យសន្តិសុខ និងបានឯកភាពធ្វើការរួមគ្នា ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មទាំងនេះ។

ក្នុងវិស័យសេដ្ឋកិច្ច **រដ្ឋមន្ត្រីការបរទេសទាំងពីរ** បានឯកភាពគ្នាថា ស្ថាប័នពាក់ព័ន្ធនៃប្រទេសទាំងពីរ គួរតែបង្កើនកិច្ចខិតខំប្រឹងប្រែងប្រើប្រាស់ឱ្យអស់សក្តានុពលដែលមាន ដើម្បីលើកកម្ពស់ពាណិជ្ជកម្ម ជាពិសេស ក្នុងវិស័យកសិកម្ម បង្កើនវំហូរវិនិយោគ និងជំរុញការបំពេញបន្ថែមឱ្យគ្នាក្នុងវិស័យសេដ្ឋកិច្ច។

ការប្រាស្រ័យទាក់ទងរវាងប្រជាជននិងប្រជាជន នៅតែជាមូលដ្ឋានគ្រឹះនៃទំនាក់ទំនងទ្វេភាគី។ **រដ្ឋមន្ត្រីការបរទេសទាំងពីរ** បានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃវិស័យទេសចរណ៍ សម្រាប់ចូលរួមលើកកម្ពស់ការយល់ដឹងពីគ្នាទៅវិញទៅមក និងបង្កើនកំណើនសេដ្ឋកិច្ច។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះការផ្តល់ជំនួយដ៏យូរអង្វែងរបស់នូវែលសេឡង់ក្នុងការអភិវឌ្ឍធនធានមនុស្ស តាមរយៈកម្មវិធីបណ្តុះបណ្តាលរយៈពេលវែង និងខ្លី ដែលបាន និងកំពុងរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍមូលធនមនុស្សនៅកម្ពុជា។

ក្រៅពីកិច្ចពិភាក្សាទ្វេភាគី **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជម្រាបជូន **ឯកឧត្តម វីនស្តុន ភីធឺរ** អំពីការវិវឌ្ឍថ្មីៗពាក់ព័ន្ធនឹងការអនុវត្តសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួរ ដែលបានចុះហត្ថលេខារវាងកម្ពុជា និងថៃ កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ និងបានគូសបញ្ជាក់ថា កម្ពុជានឹងនៅតែប្តេជ្ញាអនុវត្តតាមខ្លឹមសារ នៃសេចក្តីថ្លែងការណ៍រួមនេះ។ **ភាគីទាំងពីរ** ក៏បានផ្លាស់ប្តូរទស្សនៈអំពីការវិវត្តក្នុងតំបន់ និងអន្តរជាតិ ដែលជាផលប្រយោជន៍រួម និងបានអះអាងជាថ្មីពីការប្តេជ្ញាចិត្តរួមគ្នាក្នុងការគាំទ្រផលប្រយោជន៍ទៅវិញទៅមក និងធ្វើការរួមគ្នាដើម្បីលើកកម្ពស់សន្តិភាព ស្ថិរភាព និងវិបុលភាព តាមរយៈកិច្ចសហប្រតិបត្តិការលើឆាកអន្តរជាតិ។

**ឯកឧត្តម វីនស្តុន ភីធឺរ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** ដែលបានផ្តល់កិច្ចស្វាគមន៍យ៉ាងកក់ក្តៅ និងបដិសណ្ឋារកិច្ចដ៏ល្អប្រសើរ សម្រាប់គណៈប្រតិភូនូវែលសេឡង់។ **ឯកឧត្តម វីនស្តុន ភីធឺរ** ក៏បានអញ្ជើញ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** ទៅបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសនូវែលសេឡង់។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានឯកភាពទទួលយកការអញ្ជើញនេះដោយក្តីរីករាយ៕

ថ្ងៃសៅរ៍ ៩កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៥